**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដំណើរការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ រយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** ក្នុងពិធីបើក និងបិទ ដោយមានការអញ្ជើញចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធនិម្មិត (Zoom) ពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ មកពីគ្រប់អង្គភាពចំណុះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អង្គការវិជ្ជាជីវៈ អ្នកមានឥទ្ធិពលក្នុងបណ្តាញសង្គម និងអ្នកសារព័ត៌មានសរុបប្រមាណ ១ ០០០ នាក់។

ក្នុងរយៈពេល២ថ្ងៃនេះ អង្គសន្និបាតបានលើកយកនូវប្រធានបទចំនួន ៥ ដើម្បីធ្វើការពិភាក្សាយ៉ាងផុសផុលដោយផ្តោតលើលទ្ធផលការងារសម្រេចបាន បញ្ហាប្រឈម និងការដាក់ចេញនូវដំណោះស្រាយសម្រាប់អនុវត្តបន្តឱ្យកាន់តែមានប្រសិទ្ធភាព ដែលប្រធានបទទាំង ៥ នោះ រួមមាន៖

- ប្រធានបទទី១៖ យុទ្ធសាស្ត្រពង្រឹងសេវាការងារសាធារណៈតាមរយៈប្រព័ន្ធព័ត៌មានទីផ្សារការងារទំនើប និងការលើកកម្ពស់ប្រសិទ្ធភាពការផ្តល់សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព
- ប្រធានបទទី២៖ បរិវត្តកម្មវិស័យ អ.ប.វ. ក្នុងការផ្សារភ្ជាប់ជំនាញទៅនឹងតម្រូវការឧស្សាហកម្ម
- ប្រធានបទទី៣៖ ការពង្រឹងតួនាទីអង្គការវិជ្ជាជីវៈ និងអធិការការងារ ក្នុងការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ
- ប្រធានបទទី៤៖ ការគ្រប់គ្រង ការគាំពារជនទេសន្តរប្រវេសន៍ការងារទៅក្រៅប្រទេស និងការធ្វើសមាហរណកម្ម ប្រកបដោយប្រសិទ្ធភាព និងចីរភាព
- ប្រធានបទទី៥៖ ការពង្រឹងយន្តការស្ថាប័ន និងអនុលោមភាពនៃការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជាក្នុងបរិបទសេដ្ឋកិច្ចថ្មី និងការត្រៀមខ្លួនឆ្លើយតបនឹងហានិភ័យ និងស្ថានភាពនៃវិបត្តិ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

អង្គសន្និបាត បានឯកភាព និងសាទរចំពោះលទ្ធផលការងារសម្រេចបានគួរជាទីមោទនៈ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងឆ្នាំ២០២៥ ដោយកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវ និងបុរេសកម្មពីសំណាក់ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ រួមជាមួយកិច្ចសហការយ៉ាងជិតស្និទ្ធពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អង្គការវិជ្ជាជីវៈរបស់និយោជក អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងបងប្អូនកម្មករនិយោជិត សម្រេចបានជោគជ័យនូវអនុសាសន៍គន្លឹះ ១០ចំណុច របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាពចំនួន ២ នៃកម្មវិធីគោលនយោបាយអាទិភាពទាំង ៦ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨, គោលនយោបាយពាក់ព័ន្ធ ជាពិសេស ការអនុវត្តដោយជោគជ័យនូវវិធានការគាំទ្រ និងកិច្ចអន្តរាគមន៍ដល់បងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃ។

**ក- ការអនុវត្តអនុសាសន៍គន្លឹះ១០ចំណុចរបស់ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**

១- ទោះក្នុងស្ថានភាពសេដ្ឋកិច្ចសកលមិនមានភាពច្បាស់លាស់ ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាត្រូវបានដំឡើងជាបន្តបន្ទាប់។ ជាក់ស្តែង ប្រាក់ឈ្នួលអប្បបរមា សម្រាប់ឆ្នាំ២០២៦ របស់បងប្អូនកម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ត្រូវបានដំឡើងដោយបូកបន្ថែម ២ដុល្លារអាម៉េរិកដោយ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ដែលធ្វើឱ្យប្រាក់ឈ្នួលអប្បបរមា បានកើនឡើងដល់ចំនួន ២១០ដុល្លារអាម៉េរិកក្នុង១ខែ។ បើបូកទាំងប្រាក់អត្ថប្រយោជន៍ជាកាតព្វកិច្ចផ្សេងៗទៀត កម្មករនិយោជិតម្នាក់ៗ ទទួលបានប្រាក់ឈ្នួលទាបបំផុតចន្លោះពី ២២៧ ដុល្លារអាម៉េរិក ដល់ ២៣៨ដុល្លារអាម៉េរិកក្នុង ១ខែ។ ប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០២៦នៅកម្ពុជាគឺខ្ពស់ជាងបណ្តាប្រទេសមួយចំនួននៅអាស៊ី ដែលជាគូប្រជែងកម្ពុជា ប៉ុន្តែដោយឈរលើចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងសមត្ថភាព និងបង្កើនផលិតភាពរបស់បងប្អូនកម្មករនិយោជិត និងដោយស្មារតីស្រឡាញ់ការងារ វិជ្ជាជីវៈ និងភាពប៉ិនប្រសប់របស់បងប្អូនកម្មករនិយោជិត បានធ្វើឱ្យម្ចាស់រោងចក្រ និងវិនិយោគិនភាគច្រើនគឺអាចទទួលយកបាន។

២- បានបន្តយកចិត្តទុកដាក់អនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត សម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ដោយបានចុះបញ្ជិកាសមាជិកចំនួនប្រមាណ ៣២,៦ម៉ឺននាក់ (ស្រីប្រមាណ ១៩,៤ម៉ឺននាក់)។ គិតត្រឹមឆ្នាំ២០២៥នេះ សមាជិក ប.ស.ស. ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត មានចំនួនប្រមាណ ៨៦ម៉ឺននាក់ (ស្រីប្រមាណ ៥១,៦ម៉ឺននាក់)។

៣- បានបន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យចំនួន ១,៥លាននាក់ ដោយបានបណ្តុះបណ្តាលសិស្សប្រមាណ ១២,៥ម៉ឺននាក់ ក្នុងនោះ គ្រឹះស្ថានក្រោមឱវាទក្រសួងចំនួនប្រមាណ ១០,៩ ម៉ឺននាក់ និងក្រោមមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ចំនួនប្រមាណ ១,៦ម៉ឺននាក់។

៤- បានជំរុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងសរុបចំនួនប្រមាណ ៤,៤ម៉ឺននាក់ (ស្រីប្រមាណ ២,៨ម៉ឺននាក់) ក្នុងនោះកូនជាងបានបញ្ចប់ការហ្វឹកហ្វឺនចំនួនប្រមាណ ៣,៧ម៉ឺននាក់ (ស្រីប្រមាណ ២,៤ម៉ឺននាក់)។

៥- បានបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ របស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះសរុបចំនួនប្រមាណ ១២,៣ម៉ឺននាក់ និងកុមារអាយុក្រោម ២ឆ្នាំ ប្រមាណ ១៧ម៉ឺននាក់ ព្រមទាំងបានចំណាយថវិកាប្រមាណ ១១៣,៤ប៊ីលានរៀល។ បើគិតចាប់ពីពេលដាក់ដំណើរការកម្មវិធីដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** រហូតមកដល់ដំណាច់ឆ្នាំ២០២៥នេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះសរុបចំនួនប្រមាណ ៦៩,៧ម៉ឺននាក់ និងកុមារអាយុក្រោម ២ឆ្នាំ ប្រមាណ ៧៣,២ម៉ឺននាក់ ព្រមទាំងបានចំណាយថវិកាសរុបប្រមាណ ៤១០ប៊ីលានរៀល។

៦- បានដាក់ឱ្យអនុវត្តនូវការជ្រើសរើសពានរង្វាន់ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ប្រចាំឆ្នាំ២០២៥" និងបានប្រគល់ពានរង្វាន់ជាលើកដំបូងដល់សហគ្រាសចំនួន ៣៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ។ ទន្ទឹមនឹងនេះ ក្រសួងបានចេញសេចក្តីជូនដំណឹងស្តីពីការដាក់ពាក្យចូលរួមប្រឡងប្រណាំង "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ សម្រាប់ឆ្នាំ២០២៦"។

៧- បានជំរុញ និងលើកទឹកចិត្តឱ្យសហគ្រាស ក្រុមហ៊ុន រោងចក្រ រៀបចំ ឬផ្តល់ការឧបត្ថម្ភគាំទ្រសម្រាប់ការផ្តល់សេវាទារកដ្ឋាន ជូនដល់ទារក និងកុមារដែលជាកូនរបស់បងប្អូនកម្មករនិយោជិតតាមរយៈការបង្កើតទារកដ្ឋាន ឬបង្កើតកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មការិនីដែលមានកូនអាយុត្រឹម ២ឆ្នាំ សម្រាប់ចំណាយលើសេវាទារកដ្ឋាន អាស្រ័យតាមជម្រើសនិងតម្រូវការជាក់ស្តែងរបស់កម្មការិនីភាគច្រើននៃរោងចក្រនីមួយៗ ស្របតាមស្មារតីនៃច្បាប់ស្តីពីការងារ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងការអនុវត្តជាសកល។

៨- បានសហការជាមួយភាគីពាក់ព័ន្ធជំរុញការកែលម្អកន្លែងហូបបាយ ឬអាហារដ្ឋាន ឱ្យបានសមរម្យសម្រាប់កម្មករនិយោជិតនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលកំពុងដំណើរការចំនួន ១ ៤៧៩ និងបានជំរុញឱ្យបង្កើតថ្មីចំនួន ២២សហគ្រាស។

៩- បានដាក់ចេញកម្មវិធីឧបត្ថម្ភ និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរនូវមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតឱ្យដូចរថយន្តគំរូ ដែលស្របតាមបទដ្ឋានបច្ចេកទេស និងមានសុវត្ថិភាពនិងផាសុកភាពជាងមុននៅខេត្តស្វាយរៀង និងបន្តប្រកាសផ្សព្វផ្សាយនៅខេត្តផ្សេងៗទៀត។ បានត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតចំនួន ១ ៤២៤គ្រឿង លើរថយន្តដឹក

ជញ្ជូនកម្មករសរុបចំនួន ៣ ២៤៨គ្រឿង។ ជាមួយគ្នានេះ ក្រសួងក៏បានផ្សព្វផ្សាយអប់រំច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកចំនួន ៤០៧លើក នៅតាមសហគ្រាសសរុបចំនួន ៤០៧ ដោយមានអ្នកចូលរួមចំនួនប្រមាណ ១១,៥ម៉ឺននាក់ (ស្រីប្រមាណ ៨,៩ម៉ឺននាក់)។

១០- បានធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាពទទួលស្គាល់ជំនាញ/ការសិក្សាពីមុន (RPL) ដល់បងប្អូនកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធសរុបចំនួនប្រមាណជាង ៤៣ាន់នាក់ និងទទួលស្គាល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពសរុបចំនួន ១៥ (ឯកជនចំនួន៣) រួមទាំងបណ្តុះបណ្តាលគ្រូ/ អ្នកបច្ចេកទេសឱ្យក្លាយជា អ្នកវាយតម្លៃសមត្ថភាពបានចំនួន ៥៦៤នាក់ (ស្រី ១២៣នាក់)។

## ២. ការអន្តរាគមន៍ជួយដោះស្រាយការលំបាក និងផ្តល់ឱកាសការងារជូនបងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃ

អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** និងស្មារតីបុរេសកម្ម ក្រសួងបានចាត់កម្លាំងមន្ត្រីអន្តរាគមន៍ចុះទៅសហការយ៉ាងជិតស្និទ្ធ ជាមួយរដ្ឋបាលខេត្តជាប់ព្រំដែន អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកព្រំដែនអន្តរជាតិ សហភាពសហព័ន្ធយុវជនកម្ពុជា សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ រៀបចំមណ្ឌលសំចតនៅច្រកព្រំដែនសំខាន់ៗចំនួន ៦ មាននៅច្រកចាំយាម ខេត្តកោះកុង, ច្រកព្រំ ខេត្តប៉ៃលិន, ច្រកដូងនិងច្រកភ្នំដី ខេត្តបាត់ដំបង, ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ដោយបានចូលរួមជួយសម្រួលនីតិវិធីអាចឆ្លងដែនបានងាយស្រួល និងឆាប់រហ័ស, ផ្តល់ភេសជ្ជៈនិងអាហារសម្រន់ ជាពិសេសដល់ស្ត្រីដែលមានកុមារតូចមកជាមួយ, ផ្តល់ព័ត៌មានការងារ ព័ត៌មានកម្មវិធីបណ្តុះបណ្តាលជំនាញ និងផលប្រយោជន៍ ប.ស.ស. សម្រាប់បងប្អូនធ្វើការក្នុងប្រទេស, និងជួយជញ្ជូនសម្ភារៈរបស់បងប្អូនស្ត្រី និងបងប្អូនដែលមានកូនតូច ពីច្រកព្រំដែន រហូតដល់ទីតាំងរថយន្ត ដែលផ្តល់ដោយរាជរដ្ឋាភិបាល ដឹកជញ្ជូនបងប្អូនទៅភូមិស្រុកកំណើតដោយមិនគិតថ្លៃ។ គិតត្រឹមដំណាច់ឆ្នាំ២០២៥ ឬក្នុងរយៈពេលប្រមាណជា ៦ខែ នៃឆមាសទី២ ឆ្នាំ២០២៥ គឺមានបងប្អូនដែលរស់នៅ ឬធ្វើការនៅប្រទេសថៃប្រមាណ ៩៥ម៉ឺននាក់ បានវិលត្រឡប់មកកម្ពុជាវិញ។

បន្ថែមពីលើការទទួលស្វាគមន៍ ក្រសួងក៏សហការជាមួយសមាគមនិយោជកនានា ធនាគារ ក្រុមហ៊ុន រោងចក្រ សិប្បកម្ម ម្ចាស់ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន សហជីព បងប្អូនកម្មករនិយោជិតដែលកំពុងធ្វើការនៅតាមទីកន្លែងជាក់ស្តែងស្រាប់ និងសហភាពសហព័ន្ធយុវជនកម្ពុជា បង្កើតយុទ្ធនាការ **"ខ្មែរជួយរកការងារឱ្យខ្មែរ"** ដោយដាក់ឱ្យដំណើរការភ្លាមៗនូវ ប្រព័ន្ធស្វែងរកការងារបន្ទាន់តាមទូរសព្ទ ១២៩៧ ដែលមានអ្នកប្រចាំការ ២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្តាហ៍, ដាក់ដំណើរការប្រព័ន្ធស្វែងរកការងារតាមប្រព័ន្ធតេឡេក្រាម, ដាក់ដំឡើងផ្ទាំងប៉ាណូផ្សព្វផ្សាយព័ត៌មានឱកាសការងារនៅតាមដងផ្លូវជាតិ និងទីប្រជុំជននានាបានចំនួន ៤៦ទីតាំង ហើយគ្រោងនឹងរៀបចំឱ្យបាន១៦៥ នៅឆ្នាំ២០២៦នេះ និងចុះទៅរៀបចំវេទិកាការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចំនួន ៥៧៩លើក ដោយនាំយកឱកាសការងាររាប់ម៉ឺនកន្លែង ឱកាសចូលរៀនជំនាញដោយរាជរដ្ឋាភិបាលជាអ្នកបង់ថ្លៃជំនួសរាប់ពាន់កន្លែង និងមានតំណាងសហគ្រាស ក្រុមហ៊ុន រោងចក្រ ចុះទៅសម្ភាសផ្ទាល់តែម្តង ក្នុងខេត្តចំនួន១៧ និង ៤៣៧ឃុំ ។

ជាលទ្ធផល បងប្អូនដែលត្រឡប់ពីប្រទេសថៃប្រមាណជាង ៦២ម៉ឺននាក់ទទួលបានការងារធ្វើ ក្នុងនោះ ៣១ម៉ឺននាក់ បានទទួលការងារធ្វើនៅតាមរោងចក្រ សហគ្រាស ចំការកសិកម្មធំៗ និងក្រុមហ៊ុននានា និងចំនួនប្រមាណ ៣១ម៉ឺននាក់ផ្សេងទៀត បានទទួលការងារធ្វើនៅតាមសិប្បកម្ម ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន ការដ្ឋាន កសិដ្ឋាន ចំការ និងសកម្មភាពអាជីវកម្មនានាដែលនៅក្នុងភូមិ ឃុំ ស្រុក ក្បែរលំនៅឋានរបស់បងប្អូន។

## គ- លទ្ធផលការងារសំខាន់ៗ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨

### ១. ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម

ការពង្រឹង និងពង្រីកទីផ្សារការងារសកម្ម គឺជាគោលដៅអាទិភាពរបស់ក្រសួង ដោយក្នុងឆ្នាំ២០២៥នេះ ក្រសួងបានពង្រឹងយន្តការនៃការផ្តល់សេវាស្វែងរកការងារ តាមរយៈការរៀបចំវេទិកាជាបន្តបន្ទាប់ដូចជា វេទិកាការងារ, ពិព័រណ៍ចល័ត, ពិព័រណ៍ការងារថ្នាក់ជាតិ និងរាជធានី ខេត្ត សរុបចំនួន ១ ៣៣៩លើក មានអ្នកចូលរួមប្រមាណ ៣៤,១ម៉ឺននាក់ ព្រមទាំងបានធ្វើការផ្សព្វផ្សាយតាម ផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្មប្រភេទ LED ចំនួន ២៩ទីតាំង និងផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្មប្រភេទ PVC ចំនួន ១៧ទីតាំង នៅទូទាំងប្រទេស។

ក្នុងឆ្នាំ២០២៥នេះ ការងារចំនួនប្រមាណ ៨០ម៉ឺនកន្លែង ទាំងនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានបង្កើត និងផ្តល់ជូនបងប្អូនប្រជាពលរដ្ឋ ដែលជាកម្លាំងពលកម្មក្នុងស្រុក និងទើបឈានចូលក្នុងទីផ្សារការងារជាលើកដំបូង ឬផ្លាស់ប្តូរការងារ និងជនទេសន្តរប្រវេសន៍ខ្មែរដែលបានវិលត្រឡប់មកមាតុភូមិវិញ។

ជាមួយគ្នានេះ ក្រសួងក៏បានផ្តល់ការណែនាំ និងប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ទៅដល់សិស្ស និស្សិត អ្នកស្វែងរកការងារធ្វើ និងកម្មករនិយោជិតសរុបចំនួនប្រមាណ ៧,២ម៉ឺននាក់ (ស្រីប្រមាណ ៣,៨ម៉ឺននាក់)។ ក្រសួងបានរៀបចំសន្និសីទថ្នាក់ជាតិលើកទី២ ស្តីពីសេដ្ឋកិច្ចការងារឆ្នាំ២០២៥ ក្រោមប្រធានបទ "**ការរៀបចំអនាគតការងារនៅកម្ពុជា៖ ជំនាញមុខរបរនិងការងារ និងការគាំពារសង្គម សំដៅបង្កើតទីផ្សារការងារដែលមានភាពធន់**" ក្នុងគោលបំណងជំរុញកិច្ចសហការ ការផ្លាស់ប្តូរចំណេះដឹង និងនវានុវត្តន៍ ការស្វែងយល់ពីបញ្ហាប្រឈម និងឱកាសក្នុងការធ្វើឱ្យប្រសើរឡើងនូវទីផ្សារការងារ តាមរយៈកិច្ចពិភាក្សាគោលនយោបាយកម្រិតខ្ពស់។

ទន្ទឹមនេះ ក្រសួងបានរៀបចំបោះពុម្ពផ្សាយព្រឹត្តិបត្រ "ទស្សនវិស័យមុខរបរ និងការងារ" ចំនួន២ គឺឆមាសទី១ និងឆមាសទី២ ឆ្នាំ២០២៥ សម្រាប់យុវជន និងអ្នកធ្វើគោលនយោបាយអប់រំ ឬបណ្តុះបណ្តាលធ្វើការសម្រេចចិត្ត។

### ២. ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

នៅឆ្នាំ២០២៥នេះ ក្រសួងបានសម្រេចការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងការហ្វឹកហ្វឺនកូនជាងដល់សិក្ខាកាម សិស្ស និស្សិត និងកម្មករនិយោជិតគ្រប់កម្រិត សរុបប្រមាណ ២០,៧ម៉ឺននាក់។ ជាមួយគ្នានេះ គិតត្រឹមឆ្នាំ២០២៥ ក្រសួងបានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពចំនួន ២៥៦ គុណវុឌ្ឍិ លើ ១១៦មុខជំនាញ និងបានអភិវឌ្ឍកញ្ចប់សិក្សាផ្អែកលើសមត្ថភាពចំនួន ៣៩៩ម៉ូឌុល និង ២ ៦២០ មេរៀន លើ ៦៧គុណវុឌ្ឍិ (C1 C2 និងC3) នៃ ៦០មុខជំនាញ លើវិស័យអាទិភាពទាំង ១០។ បន្ថែមពីនេះ

ក្រសួងបានរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៨ ឆ្នាំ២០២៥ ក្រោមប្រធានបទ **"TVET បង្កើតឱកាសការងារ សាងក្តីសង្ឃឹមដល់យុវជន"** ដោយមានការតាំងបង្ហាញស្នាដៃរបស់សិស្ស និស្សិតមកពីបណ្តាគ្រឹះស្ថានជីវតនានា និងមានស្តង់ពិព័រណ៍ចំនួន ៥៥៥ស្តង់ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធចំនួន ៥៦៨ មានអ្នកចូលរួមសរុបចំនួនប្រមាណ ៦,៦ម៉ឺននាក់ (ស្រីប្រមាណ ៣ម៉ឺននាក់)។ ក្រសួងបានបញ្ជូនបេក្ខជនចូលរួមប្រកួតប្រជែងលក្ខណៈអន្តរជាតិកម្រិតតំបន់អាស៊ានចំនួន ២លើក នៅប្រទេសហ្វីលីពីន និងម៉ាឡេស៊ីដែលទទួលបានមេដាយសរុបចំនួន ៨។

ជាមួយគ្នានេះ ក្រសួងក៏បានរៀបចំថ្នាក់បង្រៀនចល័តចំនួន ៥ ព្រមទាំងបានកែច្នៃ និងបំពាក់សម្ភារៈជួសជុលថែទាំរថយន្តម៉ាស៊ីនត្រជាក់ដល់បងប្អូនអ្នកបើកបរត្រីចក្រយានយន្តបានចំនួន ៣០គ្រឿង ដើម្បីសាកល្បងបង្កើតចំណូលថ្មីដល់អ្នកមានមុខរបរបើកបរត្រីចក្រយានយន្ត។

### ៣. ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

ក្រសួងបានពង្រឹងសមត្ថភាពអធិការការងារ និងកែលម្អប្រព័ន្ធនិងវិធីសាស្ត្រធ្វើអធិការកិច្ចការងារដោយពឹងផ្អែកលើលក្ខណៈវិទ្យាសាស្ត្រ លទ្ធផលជាក់ស្តែងដែលរកឃើញដោយឧបករណ៍ សម្ភារៈ និងបរិក្ខារបច្ចេកទេស។

ក្រសួងបានធ្វើអធិការកិច្ចការងារសរុបចំនួន ១៣ ៥០០លើក ក្នុងនោះ ស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន ១២ ២០៦លើក អធិការកិច្ចការងារសាមញ្ញចំនួន ៧០៤លើក និងអធិការកិច្ចការងារពិសេសចំនួន ៥០៥លើក និងអធិការកិច្ចការងារតាមដានការដាក់កំហិតចំនួន ៨៥លើក និងពិនិត្យឃើញថាអគ្រាសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលអនុលោមភាពខ្ពស់ស្របតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យការងារ។ ទន្ទឹមនេះ តាមរយៈប្រព័ន្ធថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យវិស័យការងារ ដោយគិតត្រឹមឆ្នាំ២០២៥ ចំនួនសហគ្រាស ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកើនឡើងចំនួន ១ ៨៥១ សហគ្រាស គឺកើនពីចំនួន ៤៤ ៧៩៨ ក្នុងឆ្នាំ២០២៤ ដល់ចំនួន ៤៦ ៦៤៩សហគ្រាស ក្នុងឆ្នាំ២០២៥ ហើយចំនួនកម្មករនិយោជិតបានកើនឡើងចំនួន ៤០១ ៤៧៩នាក់ គឺកើនពីចំនួនប្រមាណ ១,៨លាននាក់ ដល់ចំនួនប្រមាណ ២,២លាននាក់ ក្នុងរយៈពេលដូចគ្នា។

ជាមួយគ្នានេះ ក្រសួងបានផ្តល់សេវាពិនិត្យកាយសម្បទាដល់ពលករ កម្មករនិយោជិតខ្មែរ និងបរទេសសរុបចំនួនប្រមាណ ១លាននាក់ (ស្រីប្រមាណ ៤៦,៦ម៉ឺននាក់) ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាល និងកម្មវិធីអប់រំជាបន្តបន្ទាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារសរុបចំនួន ៧២៤វគ្គ/លើក មានសិក្ខាកាមសរុបចំនួនប្រមាណ ១១,២ម៉ឺននាក់ (ស្រីប្រមាណ ៧,៣ម៉ឺននាក់)។ បន្ថែមពីនេះ ក្រសួងបានបន្តលើកកម្ពស់ការយល់ដឹងស្តីពីការបង្ការ និងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ តាមរយៈការផ្សព្វផ្សាយគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងក្នុងវិស័យសិប្បកម្មផលិតផល និងកសិ-ឧស្សាហកម្ម សរុបចំនួន ៤៤៧លើក/ទីតាំង មានអ្នកចូលរួមសរុបចំនួនប្រមាណ ១,៣ម៉ឺននាក់ (ស្រីប្រមាណ ៥,៣ពាន់នាក់)។

ទន្ទឹមនេះ ក្រសួងបានលើកកម្ពស់សុខដុមនីយកម្ម និងសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដោយគិតត្រឹមឆ្នាំ២០២៥នេះ ចំនួនអង្គការវិជ្ជាជីវៈកើនដល់ជិត ៧ពាន់ ក្នុងនោះសហភាពសហជីពមានចំនួន ៤២, សហព័ន្ធសហជីពមានចំនួន ២៨៤, សហជីពមូលដ្ឋានមានចំនួន ៦ ៥០៩ និងសមាគមនិយោជកមានចំនួន ១៣។ ក្រសួងបានពង្រឹងយន្តការដោះស្រាយវិវាទការងារ ដោយអត្រាសះជាវិវាទការងាររួមទាំងនៅកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៩៧,៩% និងបានពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្ម ក្នុងវិស័យការងារ ដោយបានអន្តរាគមន៍ដោះស្រាយសះជា ១០០%។

## ៤. ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ ប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព

ក្រសួងបានពង្រឹង និងពង្រីកឱកាសការងារនៅក្រៅប្រទេសជូនបងប្អូនប្រជាពលរដ្ឋ ដោយនៅឆ្នាំ២០២៥នេះ មានបងប្អូនប្រជាពលរដ្ឋ សរុបចំនួនប្រមាណ ២,៣ម៉ឺននាក់ (ស្រីប្រមាណជិត ៩ពាន់នាក់) បានចេញទៅធ្វើការនៅក្រៅប្រទេស។ គិតត្រឹមឆ្នាំ២០២៥នេះ មានជនទេសន្តរប្រវេសន៍ការងារខ្មែរកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសសរុបចំនួនប្រមាណ ៤៣,៤ម៉ឺននាក់ (ស្រីប្រមាណ ១៥ម៉ឺននាក់) ដោយបានផ្ញើប្រាក់ចូលក្នុងប្រទេស ចំនួនប្រមាណជិត ១,៨៦ប៊ីលានដុល្លារអាមេរិក។ ជាមួយគ្នានេះ ក្រសួងបានពង្រឹងសេវាគាំពារដល់ជនទេសន្តរប្រវេសន៍ការងារខ្មែរ ដោយបានចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយពលករកម្ពុជា និស្សិត និងសហគមន៍ខ្មែរនៅក្រៅប្រទេសចំនួន ២៧៤កន្លែង មានអ្នកចូលរួមចំនួនប្រមាណ ៣,១ម៉ឺននាក់ (ស្រីប្រមាណ ៩,៥ពាន់នាក់) ព្រមទាំងបានចេញសេចក្តីអំពាវនាវជាបន្តបន្ទាប់ពីការរក្សាសុវត្ថិភាព ក្នុងការធ្វើដំណើរវិលត្រឡប់របស់បងប្អូនពលករខ្មែរមកពីប្រទេសថៃ។

## ៥. ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្ត នៃស្ថានភាពសង្គម-សេដ្ឋកិច្ច

ក្នុងឆ្នាំ២០២៥នេះ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកំណើនសមាជិកផ្នែកថែទាំសុខភាពប្រមាណ ៨២ម៉ឺននាក់ ដែលធ្វើឱ្យសមាជិក ប.ស.ស. សរុបបានកើនឡើងដល់ប្រមាណ ៣,៥លាននាក់ (ស្រីប្រមាណ ១,៩លាននាក់) ក្នុងនោះ សមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួនប្រមាណ ៨៦ម៉ឺននាក់ (ស្រីប្រមាណ ៥១,៦ម៉ឺននាក់)។ ក្នុងឆ្នាំ២០២៥ មានសមាជិក ប.ស.ស. បានប្រើប្រាស់សេវាផ្នែកថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាលសរុបចំនួនប្រមាណ ៨,១លានដង (ស្រីប្រមាណ ៥,៦លានដង) ក្នុងនោះ តាមរបបភាគទានជាកាតព្វកិច្ចចំនួនប្រមាណ ៦លានដង (ស្រីប្រមាណ ៤,២លានដង) និងតាមរបបភាគទានដោយស្ម័គ្រចិត្តប្រមាណ ២,១លានដង (ស្រីប្រមាណ ១,៤លានដង) ដោយបានចំណាយតាវកាលិកប្រមាណ ៨០១,១ប៊ីលានរៀល។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះចំនួនប្រមាណ ១២,៣ម៉ឺននាក់ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួនប្រមាណ ១៧ម៉ឺននាក់ ដោយបានចំណាយថវិកាប្រមាណ ១១៣,៤ប៊ីលានរៀល។ បើគិតត្រឹមឆ្នាំ២០២៥នេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះចំនួនប្រមាណ ៦៩,៧ម៉ឺននាក់ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួនប្រមាណ ៧៣,២ម៉ឺននាក់ ដោយបានចំណាយថវិកាសរុបប្រមាណ ៤១០ប៊ីលានរៀល។

បន្ថែមលើនេះ ប.ស.ស. ជាស្ថាប័នសាធារណៈឈានមុខមួយ ដែលបានធ្វើទំនើបកម្មស្ថាប័ន និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការដាក់ឱ្យដំណើរការកម្មវិធីទូរសព្ទដៃ កម្មវិធីគេហទំព័រ និងម៉ាស៊ីនស្វ័យសេវា ព្រមទាំងប្រព័ន្ធផ្សេងៗទៀត រួមមាន **ប្រព័ន្ធសម្រាប់សហគ្រាស គ្រឹះស្ថាន និងសមាជិក ប.ស.ស.** (គេហទំព័រ NSSF Enterprise Web App, កម្មវិធីទូរសព្ទដៃ NSSF Enterprise Mobile App, កម្មវិធីទូរសព្ទដៃសម្រាប់សមាជិក NSSF Member Mobile App), **ប្រព័ន្ធសម្រាប់មូលដ្ឋានសុខាភិបាល** (ម៉ាស៊ីនស្វ័យសេវាបោះពុម្ពលិខិតប្រើប្រាស់សេវាមូលដ្ឋានសុខាភិបាល, កម្មវិធីទូរសព្ទសម្រាប់មូលដ្ឋានសុខាភិបាល Agent Mobile App, ប្រព័ន្ធគ្រប់គ្រងការចំណាយរបស់មូលដ្ឋានសុខាភិបាល H-SPIS, ប្រព័ន្ធសម្រួលការទូទាត់រវាង ប.ស.ស. និងមន្ទីរពេទ្យ), និង**ប្រព័ន្ធសម្រាប់គ្រប់គ្រងប្រតិបត្តិការការងារ ប.ស.ស.** ទាំងមូល ដូចជាប្រព័ន្ធអនុម័តឯកសារ DMS, ប្រព័ន្ធអធិការកិច្ចសន្តិសុខសង្គម ជាដើម។

## ៦. ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅ

ក្រសួងបានវិភាគមុខងារ និងរចនាសម្ព័ន្ធឡើងវិញ ស្របតាមវិធានការគន្លឹះក្នុងការជំរុញកំណែទម្រង់រដ្ឋបាលសាធារណៈ និងបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល (Document Management System - DMS) នៅថ្នាក់កណ្តាល។ ជាមួយគ្នានេះ ក្រសួងបានធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅតាមរយៈការដាក់ឱ្យអនុវត្តថ្នាលបច្ចេកវិទ្យាឌីជីថល និងបានដាក់ឱ្យដំណើរការបញ្ជរសេវាសាធារណៈចល័ត និងបានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការបញ្ជូនសារខ្លី (Push Message) ពាក់ព័ន្ធនឹង (១) កម្មវិធីអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស, (២) បេឡាជាតិសន្តិសុខសង្គម, (៣) ឱកាសការងារ, (៤) ការហាមឃាត់ការប្រើប្រាស់ពលកម្មកុមារ និង (៥) ទេសន្តរប្រវេសន៍ការងារ ទៅលេខទូរសព្ទ។ បន្ថែមពីនេះ ក្រសួងបានដាក់ឱ្យដំណើរការបញ្ជរសេវាសាធារណៈចល័ត (Mobile Public Service Counter) ឬកម្មវិធីក្នុងទូរសព្ទដៃដែលមានឈ្មោះ "MLVT Services" នៅដើមឆ្នាំ២០២៥ ដើម្បីបង្កើនភាពងាយស្រួលសម្រាប់ពលរដ្ឋខ្មែរ ដែលមានបំណងចង់ដាក់ពាក្យទៅធ្វើការនៅបរទេស នៅតាមទីតាំងមួយចំនួនដូចជា ទីស្តីការក្រសួង គ្រឹះស្ថានជីវិត បណ្ឌាសាកលវិទ្យាល័យមួយចំនួន ផ្សារទំនើប និងហាងកាហ្វេ។

ចំពោះការពង្រឹងសមត្ថភាពធនធានមនុស្ស ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការអធិការការងារ មន្ត្រីផ្សះផ្សាវិវាទការងារ រដ្ឋបាលរោងចក្រ សហជីពមូលដ្ឋានសរុបចំនួន ៤៥វគ្គ ដែលមានសិក្ខាកាមចំនួនប្រមាណ ៣,៣ពាន់នាក់ (ស្រីប្រមាណ ១,២ពាន់នាក់)។

ជាមួយគ្នានេះ ក្រសួងបានពង្រឹងសមភាពយេនឌ័រ និងសេវាសង្គម ដោយបានរៀបចំយុទ្ធនាការ ១៦ថ្ងៃ ប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ ក្រោមប្រធានបទ រួមគ្នាលើកកម្ពស់សុវត្ថិភាព និងការគោរពសិទ្ធិគ្នានៅកន្លែងការងារ ដើម្បីលើកកម្ពស់ការយល់ដឹង ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ និងជំរុញវិធានការ ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព សមភាព និងសមធម៌ មានអ្នកចូលរួមសរុបប្រមាណ ១,៨ពាន់នាក់។ បន្ថែមពីនេះ បានធ្វើតេស្តស្វែងរកសារធាតុញៀនសម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា សរុបចំនួនប្រមាណ ៤,៦ពាន់នាក់ (ស្រីប្រមាណ ១,៧ពាន់នាក់)។

ក្រសួងក៏បានបន្តពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ តាមរយៈការចុះហត្ថលេខាលើអនុស្សរណៈ កិច្ចព្រមព្រៀង និងគម្រោងជាមួយដៃគូសំខាន់ៗ

ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យការងារ និងជីវភាព។ ជាមួយគ្នានេះដែរ ក្រសួងបានចូលរួមយ៉ាងសកម្មក្នុងវេទិកាក្នុងតំបន់និងអន្តរជាតិនានា ដូចជាកិច្ចប្រជុំសន្និសីទអន្តរជាតិខាងការងារ កិច្ចប្រជុំអាស៊ាន និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកបន្តអនុវត្តគម្រោងសំខាន់ៗមានជាអាទិ៍៖ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា, កម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជា, កម្មវិធីមុខរបរ និងការងារសមរម្យសម្រាប់យុវជននៅកម្ពុជា, កាតាលីករសកលស្តីពីការងារសមរម្យ និងការគាំពារសង្គមសម្រាប់អន្តរកាលយុត្តិធម៌។

### ឃ. ទិសដៅការងារសម្រាប់ឆ្នាំ២០២៦

១. បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍គន្លឹះទាំង ១០ចំណុចរបស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**។

២. បន្តពង្រឹង និងពង្រីកការផ្តល់សេវាការងារ សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ការតម្រង់ទិសមុនចូលទីផ្សារការងារ និងការបន្តរៀបចំព្រឹត្តិការណ៍ការងារ រួមមាន វេទិកាការងារ ពិព័រណ៍ការងារ និងការផ្គូផ្គងនិងសម្ភាសការងារ និងការពង្រឹងប្រសិទ្ធភាពនៃដំណើរការប្រព័ន្ធស្វែងរកការងារបន្ទាន់តាមទូរសព្ទ ១២៩៧ ដល់សាធារណៈ និងជាពិសេសបងប្អូនដែលត្រឡប់មកពីប្រទេសថៃ។

៣. បន្តពង្រីកទីផ្សារការងារនៅក្រៅប្រទេស ដែលមានប្រាក់ឈ្នួលខ្ពស់ លក្ខខណ្ឌការងារល្អ និងមានជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

៤. បន្តរៀបចំ ផលិត និងផ្សព្វផ្សាយរបាយការណ៍អង្កេតនិងឯកសារសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងតម្រូវការទីផ្សារការងារ ជាពិសេស ទស្សនវិស័យមុខរបរនិងការងារ ឱ្យបានទៀងទាត់ ដើម្បីផ្តល់ព័ត៌មានទីផ្សារការងារឱ្យបានគ្រប់ជ្រុងជ្រោយ ដល់អ្នកស្វែងរកការងារ កម្មករនិយោជិត និយោជក អ្នកផ្តល់ការបណ្តុះបណ្តាល និងសាធារណជន។

៥. បន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ ការគាំពារជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅក្រៅប្រទេស និងយន្តការសមាហរណកម្មជនទេសន្តរប្រវេសន៍ការងារខ្មែរប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

៦. បន្តពង្រឹងយន្តការអធិការកិច្ចអន្តរក្រសួង និងប្រព័ន្ធអភិបាលកិច្ចអធិការកិច្ចការងារតាមរយៈការកំណត់គុណវុឌ្ឍិអធិការការងារ និងយុទ្ធសាស្ត្រអធិការកិច្ចការងារផ្អែកលើកម្រិតហានិភ័យរបស់សហគ្រាស ក្រុមហ៊ុន រោងចក្រ សំដៅបង្កើនជំនឿទុកចិត្តរបស់និយោជក កម្មករនិយោជិត និងភាគីពាក់ព័ន្ធលើអធិការការងារ ដោយឈរលើអភិក្រមអនុវត្តចំនួន ៤ ដូចខាងក្រោម៖

   ៦.១. គោលដៅចុងក្រោយនៃការធ្វើអធិការកិច្ចការងារ មិនមែនការផាកពិន័យទេ គឺជាការធានានូវអនុលោមភាពនៃច្បាប់លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាប្រតិបត្តិ។

   ៦.២. រៀបចំឯកសារទាំងជាអក្សរ ជាសំឡេង ជាវីដេអូ ដើម្បីពន្យល់ បកស្រាយ ដោយលំហូរការងារជាភាសាសាមញ្ញ ងាយយល់ សម្រាប់សាធារណជនទូទៅ។

   ៦.៣. អធិការការងារ អធិការពេទ្យការងារ និងមន្ត្រីផ្សះផ្សាត្រូវមានសមត្ថភាពយល់ដឹង និងបកស្រាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ប្រកបដោយសង្គតិភាព ព្រមទាំងជំរុញការអនុវត្តស្វ័យប្រកាសអធិការកិច្ចការងារ។

៦.៤. ផ្តល់ការបណ្តុះបណ្តាលដល់មុខសញ្ញាដែលងាយរងហានិភ័យឱ្យយល់ដឹងពីយន្តការជូនដំណឹងដល់ក្រសួង និងមន្ត្រីមានសមត្ថកិច្ច មុនគេ។

៧. បន្តលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ នៅកន្លែងការងារ តាមរយៈការពង្រឹងសមត្ថភាពរបស់ "គណៈកម្មការសុវត្ថិភាព និងសុខភាពការងារនៅតាមសហគ្រាស" ដែលមានស្រាប់ និងបន្តសហការជាមួយដៃគូអភិវឌ្ឍន៍ និងដៃគូសង្គមបំពាក់សម្ភារៈ បរិក្ខារស្វ័យប្រវត្តិដោយភ្ជាប់នឹងប្រព័ន្ធតាមដានជាសកល និងដាក់ផ្ទាំងព័ត៌មាន (LED) ពាក់ព័ន្ធនឹងបទដ្ឋានសុវត្ថិភាពនិងសុខភាពការងារ (OSH) នៅក្នុងអគារផលិតកម្មនីមួយៗ ដើម្បីប្រតិភូបុគ្គលិកនិងបងប្អូនកម្មករនិយោជិត អ្នកបញ្ជាទិញ និងអធិការពេទ្យការងារអាចតាមដាន និងវាយតម្លៃស្ថានភាពជាក់ស្តែងបានគ្រប់ពេលវេលា ដោយផ្តើមចេញពីវិស័យកាត់ដេរ ហើយនិយោជកនឹងមិនមានបន្ទុកចំណាយលើការដាក់ឱ្យដំណើរការប្រព័ន្ធនេះឡើយ។ បន្តសហការជាមួយដៃគូនិងភាគីពាក់ព័ន្ធបញ្ចប់ សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ (OSH)។

៨. បង្កើនកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងការលុបបំបាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ជាពិសេសក្នុងវិស័យដែលមានហានិភ័យខ្ពស់។

៩. បន្តអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ប្រតិភូបុគ្គលិក បុគ្គលទទួលបន្ទុកផ្នែករដ្ឋបាលនិងធនធានមនុស្ស និយោជក និងកម្មករនិយោជិត ក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ។

១០. បន្តពង្រឹងប្រសិទ្ធភាព យន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ តាមរយៈការដាក់ចេញនូវយន្តការបង្ការ និងដោះស្រាយវិវាទការងារនៅកម្រិតសហគ្រាស និងការអភិវឌ្ឍសមត្ថភាពអ្នកផ្សះផ្សាវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល។

១១. បន្តពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គម ឱ្យបានជាអតិបរមា តាមរយៈការសិក្សាសមិទ្ធិលទ្ធភាពនៃការពង្រីកនិងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ចុះបញ្ជីក្រុមគោលដៅដែលមិនទាន់គ្របដណ្តប់តាមរយៈកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ពិសេសអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

១២. បន្តលើកកម្ពស់អនុលោមភាពនៃការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូទាំងអស់ និងរៀបចំវេទិកាជាមួយតំណាងភាគីពាក់ព័ន្ធ (មូលដ្ឋានសុខាភិបាល ធនាគារដៃគូ ភាគីនិយោជក និងតំណាងសមាជិក ប.ស.ស.) ជារៀងរាល់ត្រីមាស ដើម្បីពិភាក្សាដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានា សំដៅលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពនៃការផ្តល់សេវារបស់ ប.ស.ស. ឱ្យកាន់តែប្រសើរឡើង។

១៣. បន្តជំរុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសជូនដល់យុវជនគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យចំនួន ១,៥លាននាក់ ឱ្យស្របទៅតាមតម្រូវការឧស្សាហកម្ម និងជំរុញការអនុវត្តការទទួលស្គាល់ជំនាញពីមុន របស់បងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃ ក្នុងវិស័យអាទិភាព ដែលចាប់ផ្តើមពីវិស័យសំណង់ លើ ៨មុខជំនាញ នៅក្នុងខែមេសា ឆ្នាំ២០២៦ ខាងមុខនេះ ដោយរាជរដ្ឋាភិបាល ជាអ្នកបង់ថ្លៃធ្វើតេស្តជំនួស។

១៤. បន្តជំរុញនិងផលិតថ្នាក់បណ្តុះបណ្តាលចល័តឱ្យកាន់តែច្រើន និងទំនើបដើម្បីបង្វិតការបណ្តុះបណ្តាលឱ្យកាន់តែជិតអ្នកដែលមានតម្រូវការក្នុងការបណ្តុះបណ្តាល។ ពង្រីកការកែច្នៃម៉ូតូកង់បី ដើម្បីបង្កើនចំណូលដល់អ្នកមានមុខរបរបើកបរត្រីចក្រយានយន្ត ឬលក់ដូរចល័ត។

១៥. ចូលរួមជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តឱ្យបានជោគជ័យកម្មវិធីគន្លងអប់រំថ្មី ដែលនឹងចាប់ផ្តើមអនុវត្តសាកល្បងចាប់ពីឆ្នាំសិក្សា២០២៦-២០២៧ តទៅ សំដៅផ្តល់ជម្រើសបន្ថែមដល់សិស្សវិទ្យាល័យ ដែលស្ថិតនៅក្បែរតំបន់សេដ្ឋកិច្ចពិសេស ឬសួនឧស្សាហកម្ម ហើយមានបំណងចូលទៅកាន់ទីផ្សារការងារលឿន អាចជ្រើសរើសយកគន្លងវិជ្ជាជីវៈ នៅវិទ្យាល័យរបស់ខ្លួន។

១៦. បញ្ចប់គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។

១៧. បន្តពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាព ប្រសិទ្ធភាព និងគុណភាពនៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

១៨. បន្តពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចនិងរដ្ឋបាលការងាររបស់ក្រសួង តាមរយៈការធ្វើឌីជីថលនីយកម្មបន្ថែមទៀតនូវរាល់សកម្មភាពអធិការកិច្ចការងារ សេវាសាធារណៈ និងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យវិស័យការងារ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការបណ្តុះបណ្តាលជំនាញ ប្រព័ន្ធគ្រប់គ្រងទិន្នន័យសន្និធិជំនាញ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការធ្វើតេស្តសមត្ថភាពជំនាញពីមុន ប្រព័ន្ធគ្រប់គ្រងទិន្នន័យបេឡាជាតិសន្តិសុខសង្គម និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពការងារនៅកន្លែងធ្វើការ ព្រមទាំងបំពាក់បន្ថែមនូវសម្ភារៈនិងឧបករណ៍វៃឆ្លាតដើម្បីជាជំនួយដល់ក្រុមអធិការកិច្ចការងារ និងអង្គភាពក្រោមឱវាទក្រសួង។

១៩. រៀបចំសេចក្តីណែនាំជាឯកសារ ជាសំឡេង និងជាឃ្លីបវីដេអូ ដោយប្រើភាសាសាមញ្ញ និងលំហូរការងារកាន់តែសាមញ្ញថែមទៀតសំដៅឱ្យតួអង្គពាក់ព័ន្ធគ្រប់ស្រទាប់វណ្ណៈ អាចយល់ និងចូលរួមអនុវត្តកាន់តែច្រើន និងល្អស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ឧត្តមានុវត្តន៍ជាសកល ដែលពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១១កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦